# សេចក្តីថ្លែងការណ៍រួម

## ស្តីពី ការព្រួយបារម្ភអំពីការរឹតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ អ្នកការពារសិទ្ធិមនុស្សនៅក្នុងបញ្ហាទំនាស់ដីធ្លី នៅក្នុងប្រទេសកម្ពុជា

*ភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១*

អង្គការសង្គមស៊ីវិលកម្ពុជា ដែលរួមមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានគាំទ្រសេចក្តីថ្លែងការណ៍រួម ដូចមានឈ្មោះខាងក្រោម សំដែងនូវការសោកស្តាយយ៉ាងខ្លាំងចំពោះការប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីរឹតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់សកម្មជនការពារសិទ្ធិមនុស្ស ក្នុងការបំពេញភារកិច្ច ដើម្បីការពារ និងទាមទាររកយុត្តិធម៌ សំរាប់ជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលចេះតែកើនឡើងជាលំដាប់ និងខ្វះការយកចិត្តទុកដាក់។

ជាក់ស្តែងកាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ សាលាដំបូងខេត្តកំពង់ឆ្នាំង បានចេញសេចក្តីសំរេចផ្តន្ទាទោស លោក **សំ ច័ន្ទគា** ដែលជាសកម្មជនការពារសិទ្ធិមនុស្សមួយរូប និងជាអ្នកសំរបសំរួលការិយាល័យខេត្តកំពង់ឆ្នាំង នៃសមាគមការពារសិទ្ធិមនុស្សអាដហុក ពីបទ “**បរិហារកេរ្តិ៍**” យោងតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌថ្មីរបស់ព្រះរាជាណាចក្រកម្ពុជា ដែលទើបតែចូលជាធរមាន កាលពីអំឡុងចុងឆ្នាំ២០១០ ដោយបានបង្គាប់ឱ្យលោកបង់ប្រាក់ពិន័យចំនួន ១ លាន រៀល និងប្រាក់សំណងជំងឺចិត្តទៅភាគីដើមចោទ ចំនួន ៣ លាន រៀល បន្ថែមទៀត។ មួយសប្តាហ៍មុននេះ សាលាដំបូងខេត្ត ក៏បានសំរេចផ្តន្ទាទោស លោក **រាជ សីមា** ដែលជាតំណាងប្រជាពលរដ្ឋដែលមានទំនាស់ដីធ្លីជាមួយក្រុមហ៊ុនដូចគ្នា ពីបទ “**បរិហារកេរ្តិ៍**” ផងដែរ ដោយត្រូវបង្គាប់ឱ្យបង់ប្រាក់ពិន័យចំនួន ២ លានរៀល និងប្រាក់សំណងជំងឺចិត្តចំនួន ៨ លានរៀល ជាទំហំទឹកប្រាក់ដ៏ច្រើនសម្បើម ហើយដែលអាចធ្វើឱ្យគាត់ប្រឈមនឹងការដាក់ពន្ធនាគារជំនួសវិញ ប្រសិនបើគាត់មិនអាចធ្វើតាមសេចក្តីសំរេចនេះបាន។

ការសង្កេតឃ្លាំមើលរបស់អង្គការសង្គមស៊ីវិលចំពោះករណីនេះ បង្ហាញថា ព្រះរាជអាជ្ញា នៃសាលាដំបូងខេត្តកំពង់ឆ្នាំង បានធ្វើការចោទប្រកាន់សកម្មជនការពារសិទ្ធិមនុស្ស លោក សំ ច័ន្ទគា ដោយគ្រាន់តែផ្អែកលើការផ្តល់យោបល់ផ្នែកច្បាប់ទាក់ទិននឹងករណីដីធ្លីមួយកន្លែង ស្ថិតនៅភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលកំពុងតែនៅមានទំនាស់រវាងភាគីប្រជាពលរដ្ឋនៅតំបន់នោះជាមួយនឹងក្រុមហ៊ុនខេ.ឌី.ស៊ី. អន្តរជាតិ (KDC International) របស់លោកជំទាវ **ជា ខេង** ភរិយារបស់លោករដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ នៅក្នុងបទសំភាសន៍មួយជាមួយនឹងវិទ្យុអាស៊ីសេរី ដែលបានចាក់ផ្សាយកាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៩ ជុំវិញបញ្ហាឈូសឆាយដីមានទំនាស់នេះ លោក សំ ច័ន្ទគា ត្រូវបានដកស្រង់សំដីថា: “*អ្វីដែលក្រុមហ៊ុនធ្វើនេះបំពានទៅហើយ ពីព្រោះតុលាការមិនទាន់សំរេចដល់អង្គសេចក្តីនៅឡើយទេ អ៊ីចឹងហើយ ក្រុមហ៊ុនគួរតែត្រូវផ្អាករង់ចាំការសំរេចដោយអង្គសេចក្តីសិន* ”។ ការសំដែងទស្សនៈបែបនេះ ក៏ត្រូវបានទទួលស្គាល់ក្នុងមាត្រា ១៣៦ និង ១៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីថ្មី របស់ព្រះរាជាណាចក្រកម្ពុជា ផងដែរ។

ការចោទសួរនៅក្នុងសវនាការសាលាដំបូងខេត្ត កាលពីព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ បានគូសបញ្ជាក់ថា នៅមុនពេលផ្តល់សំភាសន៍សំដែងមតិទស្សនៈផ្នែកច្បាប់តាមរយៈវិទ្យុអាស៊ីសេរីនេះ លោក សំ ច័ន្ទគា ក៏ធ្លាប់បានទទួលសំណើសុំពីប្រជាពលរដ្ឋទាក់ទិននឹងករណីទំនាស់ដីធ្លី ដែលពួកគាត់បានតវ៉ាជាមួយនឹងតំណាងក្រុមហ៊ុន KDC International តាំងពីឆ្នាំ ២០០១ មកម្ល៉េះ ហើយក៏បានទទួលឯកសារពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋដែលបានប្តឹងចូលតុលាការខេត្តកំពង់ឆ្នាំង កាលពីខែឧសភា ឆ្នាំ២០០៩ ដែលរហូតមកទល់ពេលនេះ សាលាដំបូងខេត្តកំពង់ឆ្នាំងបានទទួលពាក្យបណ្តឹងហើយ តែមិនចាត់វិធានការដោះស្រាយជូនប្រជាពលរដ្ឋ។ ឯកសារទាំងពីរខាងលើនេះ ក៏ជាភស្តុតាងបង្ហាញយ៉ាងច្បាស់ថា ដីធ្លីនៅតំបន់នោះមិនទាន់ត្រូវបានដោះស្រាយដាច់ស្រេចអំពីកម្មសិទ្ធិដីធ្លីនៅឡើយ។

ដូចនេះ ជាមួយនឹងករណីខាងលើអង្គការសង្គមស៊ីវិលកាន់តែមានការព្រួយបារម្ភអំពីការអនុវត្តន៍ច្បាប់ និងយល់ឃើញថា សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ (ទោះជាទស្សនៈ/យោបល់ផ្នែកច្បាប់ ឬទស្សនៈធម្មតាក្តី) ត្រូវបានតុលាការយកមកបកស្រាយក្នុងក្របខណ្ឌដ៏តូចចង្អៀត ហើយអ្នកដែលហ៊ានសំដែងមតិ ទោះជាក្នុងក្របខណ្ឌច្បាប់ក៏ដោយ ក៏ងាយត្រូវប្រឈមនូវការចោទប្រកាន់ និងផ្តន្ទាទោសអំពីបទ "បរិហារកេរ្តិ៍" ដែលនេះ ជាការរួមតូចនៃបរិយាកាសការងាររបស់អ្នកការពារសិទ្ធិមនុស្ស ក្នុងការបំពេញតួនាទីជាអ្នកការពារសិទ្ធិមនុស្ស ក្នុងការទាមទាររកយុត្តិធម៌ដល់ជនរងគ្រោះទន់ខ្សោយប្រឆាំងនឹងអ្នកមានអំណាច ឬអ្នកមានទឹកប្រាក់។ លើសពីនេះទៀត ទង្វើបែបនេះ ក៏នឹងធ្វើឱ្យអ្នកការពារសិទ្ធិមនុស្សដទៃផ្សេងទៀត លែងហ៊ានសំដែងនូវទស្សនៈអំពីព្រឹត្តិការណ៍អ្វីមួយ ឬចូលរួមក្នុងសកម្មភាពការពារ និងលើកស្ទួយសិទ្ធិមនុស្ស ឬជួយស្វែងរកយុត្តិធម៌ជូនដល់ក្រុមមនុស្សដែលទទួលរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្ស ទោះជាសេរីភាពក្នុងការសំដែងមតិបែបនេះ ត្រូវបានគាំពារយ៉ាងពេញលេញដោយរដ្ឋធម្មនុញ្ញ និងកតិកាសញ្ញាអន្តរជាតិទាក់ទិននឹងបញ្ហាសិទ្ធិមនុស្ស ដែលប្រទេសកម្ពុជាផ្តល់សច្ចាប័នហើយ ក៏ដោយ។

ជុំវិញករណីលោក **សំ ច័ន្ទគា** និងលោក **រាជ សីមា** យើងខ្ញុំសង្ឃឹមថា តុលាការជាន់ខ្ពស់នឹងពិនិត្យពិចារណា និងសំរេចបដិសេធចោលនូវសាលក្រមទាំងនេះ។ ម្យ៉ាងទៀត ទាក់ទិនទៅនឹងបញ្ហានេះ អង្គការសង្គមស៊ីវិលក៏សូមអំពាវនាវដល់អ្នកដែលមានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីឱ្យពិនិត្យមើលនូវបទប្បញ្ញត្តិ "បរិហាកេរ្តិ៍" នេះ ធ្វើយ៉ាងណាឱ្យការអនុវត្តន៍ និងការបកស្រាយបទប្បញ្ញត្តិនេះ មិនប៉ះពាល់ទៅដល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ដែលត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា។ ជាងនេះទៀត យើងខ្ញុំក៏ទទូចសុំឱ្យរាជរដ្ឋាភិបាល និងស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ មេត្តាគិតគូរដល់សេរីភាពក្នុងការសំដែងមតិឱ្យបានពេញលេញ តាមរយៈការពន្លឿនការកែទំរង់ប្រព័ន្ធច្បាប់ និងតុលាការ ឱ្យបានឆាប់រហ័ស និងការធានានូវរាល់សកម្មភាពបំពេញតួនាទីដោយត្រឹមត្រូវរបស់អ្នកការពារសិទ្ធិមនុស្សនានានៅក្នុងប្រទេសសំរាប់ជាប្រយោជន៍យុត្តិធម៌សង្គម ដោយមិនត្រូវបានទទួលរងនូវការរំខានផ្សេងៗ ទាំងផ្នែកច្បាប់ និងទាំងផ្នែកនយោបាយ ដើម្បីឱ្យស្របតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនក្នុងឋានៈជារដ្ឋហត្ថលេខី នៃកតិកាសញ្ញាអន្តរជាតិទាក់ទិននឹងសិទ្ធិមនុស្ស និង បានទទួលស្គាល់សេចក្តីប្រកាសស្តីពីការការពារអ្នកការពារសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

*ខាងក្រោមនេះ ជាឈ្មោះអង្គការសង្គមស៊ីវិល (សមាគម និងអង្គការមិនមែនរដ្ឋាភិបាល) ដែលគាំទ្រសេចក្តីថ្លែងការណ៍រួមនេះ*

| ល.រ | ឈ្មោះសមាគម/អង្គការមិនមែនរដ្ឋាភិបាល |
|---|---|
| ១ | សមាគមការពារសិទ្ធមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) |
| ២ | ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) |
| ៣ | អង្គការលីកាដូ (LICADHO) |
| ៤ | វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID) |
| ៥ | មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៏ (CLEC) |
| ៦ | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) |
| ៧ | សមាគមយុវជនខ្មែរ (KYA) |
| ៨ | មជ្ឈមណ្ឌលកម្ពុជាដើម្បីស្រ្តីមានវិបត្តិ (CWCC) |
| ៩ | អង្គការជំនួយផ្នែកច្បាប់ នៃកម្ពុជា (LAC) |
| ១០ | អង្គការខារ៉ាមកម្ពុជា (CARAM Cambodia) |
| ១១ | មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR) |
| ១២ | សម្ព័ន្ធសិទ្ធិមនុស្ស និង សុខភាពកម្ពុជា (CHHRA) |
| ១៣ | សមាគមសិទ្ធិមនុស្សចាម-ខ្មែរឥស្លាមជនជាតិភាគតិច និងអភិវឌ្ឍន៏ (CKIMHRDA) |
| ១៤ | បេសកកម្មសម្ព័ន្ធសប្បុរសធម៌ខ្មែរ (GENEROUS) |
| ១៥ | អង្គការការពារសិទ្ធិមនុស្សដើម្បីតម្លាភាព និងសន្តិភាព (HROTP) |
| ១៦ | សមាគមឥន្រ្ទទេវី (IDA) |
| ១៧ | វិទ្យាស្ថានខ្មែរដើម្បីអភិវឌ្ឍន៍ជាតិ (KIND) |
| ១៨ | អង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស (KKKHRO) |
| ១៩ | សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៏ (KKKHRDA) |
| ២០ | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៏ និងសន្តិភាព (PDP) |
| ២១ | អង្គការការពារយុត្តិធម៌កុមារ (PJJ) |
| ២២ | អង្គការរក្សាការពារសិទ្ធិមនុស្ស នៃកម្ពុជា (VIGILANCE) |
| ២៣ | មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) |
| ២៤ | មជ្ឈមណ្ឌលដើម្បីយុត្តិធម៌ និងការបង្រួបបង្រួម (CJR) |
| ២៥ | អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV) |
| ២៦ | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) |
| ២៧ | វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) |
| ២៨ | សមាគមនិស្សិតខ្មែរ (KSA) |